**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
**លេខ: ០១៥/០៨ របក.អគគ**

## របាយការណ៍ ស្តីពី សកម្មភាពការងារប្រចាំខែ មិថុនា ឆ្នាំ ២០០៨ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ មិថុនា ឆ្នាំ ២០០៨ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្ម ដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេច បាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

### ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

### ក. ការងាររដ្ឋបាល

-ផ្ញើលិខិតអញ្ជើញ ចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៨

-ផ្ញើលិខិតស្នើសុំជួបពិភាក្សាការងារតុលាការគំរូ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៨ នៅសាលាដំបូងក្រុងភ្នំពេញ និងស្នើសុំជួបពិភាក្សាផងដែរ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៨ នៅសាលាដំបូងខេត្តកំពង់ចាម

-ផ្ញើលិខិតអញ្ជើញចូលរួមពិធីចុះហត្ថលេខាលើអនុសារណៈ ស្តីពីការយោគយល់គ្នារវាងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងគម្រោងកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការនៃអង្គការ GTZ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៨

-ផ្ញើដីកាអមរបាយការណ៍ ស្តីពីកិច្ចប្រជុំក្រុមការងារជាន់ខ្ពស់សម្រាប់គម្រោងតុលាការគំរូ ដើម្បីអនុម័ត លើសេចក្តីព្រាងឯកសារស្តីពីស្តង់ដារ និងលក្ខណៈវិនិច្ឆ័យសម្រាប់តុលាការគំរូកម្ពុជា

-ផ្ញើលិខិតជូនទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ ស្តីពីទិន្នន័យរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ សម្រាប់សេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០០៨ នៃការអនុវត្ត ជយអជ

-ផ្ញើលិខិតអញ្ជើញចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីប្រភពធនធាននៃការបណ្តុះបណ្តាលសិទ្ធិមនុស្ស ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ នៅសណ្ឋាគារភ្នំពេញ

-ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៨

**ខ. ការងារកំណែទម្រង់**

-បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ ដែលនឹងប្រព្រឹត្តទៅ នៅ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៨

-បានជួបពិភាក្សាការងារតុលាការគំរូ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៨ នៅតុលាការក្រុងភ្នំពេញ

-បានរៀបចំពិធីចុះហត្ថលេខាលើអនុសារណៈ ស្តីពីការឃោគយល់គ្នារវាងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងគម្រោងកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការនៃអង្គការ GTZ ដែលនឹងប្រព្រឹត្ត ទៅ នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៨ ដែលមានសមាសភាពអ្នកចូលរួម ៦០នាក់

-បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីប្រភពធនធាននៃការបណ្តុះបណ្តាលសិទ្ធិមនុស្ស ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ នៅសណ្ឋាគារភ្នំពេញ ដែលមានសមាសភាពអ្នកចូលរួមចំនួន ៦០នាក់

**គ. ផ្សេងៗ**

-បន្តរៀបចំសូចនាករតាមក្រុមគម្រោងទាំងអស់នៃអង្គភាពគ្រប់គ្រងគម្រោង

**២-សន្និដ្ឋាន**

ក្នុងខែ មិថុនា ឆ្នាំ ២០០៨ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានជួបពិភាក្សាការងារតុលាការគំរូ នៅតុលាការក្រុងភ្នំពេញ ដើម្បីបន្តដំណើរការរបស់គម្រោងតុលាការគំរូ ថ្នាក់គ្រប់គ្រងតុលាការ ដែលត្រូវបានជ្រើសរើសជាតុលាការគំរូ និងដើម្បីរៀបចំផែនការការងារសំដៅលើក កំពស់តុលាការគំរូនីមួយៗ ឱ្យឆ្លើយតបទៅនឹងស្តង់ដារដែលបានកំណត់។ អង្គភាពគ្រប់គ្រងគម្រោង ក៏បានរៀបចំសិក្ខា-សាលាផ្សព្វផ្សាយ ស្តីពីប្រភពធនធាននៃការបណ្តុះបណ្តាលសិទ្ធិមនុស្ស និងបានចុះអនុសារណៈ ស្តីពីការឃោគយល់គ្នាជាមួយនឹងគម្រោងកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការនៃអង្គការ GTZ។

**៣-ទិសដៅអនុវត្តក្នុងខែបន្ត**

-បន្តជម្រុញការអនុវត្តគម្រោងតុលាការគំរូ

-បន្តជម្រុញការអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដាន

-បន្តជម្រុញការអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន

រាជធានី ភ្នំពេញ ថ្ងៃទី ខែកក្កដា ឆ្នាំ២០០៨

អ្នកធ្វើរបាយការណ៍

ហ៊ួង សុកុល

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង

ស៊ុយ ម៉ុងលាង